**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

*ថ្ងៃចន្ទ ៩រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃចន្ទ ៩រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (DOAG) រដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងផ្តល់ហិរញ្ញប្បទានឥតសំណងប្រមាណ ៦២ លានដុល្លារអាមេរិក សម្រាប់ឆ្នាំទី១ នៃកិច្ចព្រមព្រៀង ៥ឆ្នាំនេះ ដោយក្នុងនោះ ហិរញ្ញប្បទានប្រមាណ ៤១,៦ លានដុល្លារ សម្រាប់វិស័យសុខាភិបាល និងអប់រំ និង ២០,៥ លានដុល្លារ សម្រាប់វិស័យកសិកម្ម និងបរិស្ថាន ដែលអនុវត្តដោយភ្នាក់ងារអនុវត្តគម្រោងនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

តាមរយៈកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (DOAG) ដែលទើបតែចុះហត្ថលេខានេះ ហិរញ្ញប្បទានប្រមាណ ៣៣៨ លានដុល្លារអាមេរិក នឹងគ្រោងផ្តល់ដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក សម្រាប់រយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០២១-២០២៥ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងចីរភាព តាមរយៈការអនុវត្តគម្រោងក្នុងវិស័យកសិកម្ម និងបរិស្ថាន ព្រមទាំងការពង្រឹងសេវាសុខភាព, អប់រំ និងគាំពារកុមារផងដែរ។

គិតចាប់តាំងពីឆ្នាំ១៩៩២ រហូតដល់ឆ្នាំ២០២១ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានផ្តល់ហិរញ្ញប្បទានការគាំទ្រដល់ប្រទេសកម្ពុជាប្រមាណ ១,៧ ពាន់លានដុល្លារ សម្រាប់គាំទ្រដល់វិស័យអាទិភាពដូចជា វិស័យសុខាភិបាល, អប់រំ, បរិស្ថាន, កសិកម្ម, អភិបាលកិច្ច, ការអភិវឌ្ឍបែបប្រជាធិបតេយ្យ និងកម្មវិធីដោះមីន

និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលឆ្លើយតបទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សូមថ្លែងអំណរគុណចំពោះ រដ្ឋាភិបាល និងប្រជាជនអាមេរិក ដែលបន្តការគាំទ្រ និងប្តេជ្ញារួមចំណែកក្នុងកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ប្រកបដោយបរិយាប័ន្ន និងចីរភាព ជាពិសេសសម្រាប់ការរួមចំណែកក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជា។ ទន្ទឹមនេះ រដ្ឋាភិបាលសហរដ្ឋអាមេរិកក៏បានកោតសរសើរ ចំពោះការបន្តកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជាប្រយោជន៍រួមដល់ប្រទេសទាំងពីរ។